# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 23-Nov-2011, 11:42
CMS/CFO: Sann Rada

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ
ភាគីដាក់ឯកសារ: សហមេធាវីការពារក្តីរបស់លោក អៀង សារី
ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង
ភាសាដើម: អង់គ្លេស
កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ២០១១

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ**
ចំណាត់ថ្នាក់ឯកសារដោយ អង្គជំនុំជម្រះ **សាធារណៈ/Public**
ចំណាត់ថ្នាក់ប្រភេទឯកសារ
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន:
ឈ្មោះមន្ត្រីកត់ត្រា:
ហត្ថលេខា:

---

**សំណើរបស់លោក អៀង សារី ស្នើសុំឲ្យមានដំណោះស្រាយឆ្លាមៗ និងមានសេចក្តីសម្រេច ដែលមានសំអាងហេតុគ្រប់គ្រាន់ចំពោះបញ្ហានានាដែលនៅមិនទាន់បានដោះស្រាយ មុនពេល ចាប់ផ្តើមដំណើរការសវនាការ**

---

**សហមេធាវីការពារក្តី:**
លោក អាង ឧត្តម
លោក Michael G. KARNAVAS

**ដាក់ជូន ÷**
**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម **និល ណុន** ប្រធាន
ចៅក្រម **យ៉ូរ ឧត្តរា**
ចៅក្រម **យ៉ា សុខន**
ចៅក្រម Silvia CARTWRIGHT
ចៅក្រម Jean-Marc LAVERGNE

ចៅក្រមបម្រុង **ឆូ មណី**

ចៅក្រមបម្រុង Claudia FENZ

**សហព្រះរាជអាជ្ញា**

លោកស្រី ជា លាង

លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**

**ដើមបណ្ដឹងរដ្ឋប្បវេណីទាំងអស់**

លោក អៀង សារី តាមរយៈសហមេធាវីការពារក្តីរបស់ខ្លួន (“មេធាវីការពារក្តី”) សូមដាក់សំណើសុំឱ្យមានដំណោះស្រាយភ្លាមៗចំពោះបញ្ហានានាដែលនៅមិនទាន់បានដោះស្រាយ មុនពេលចាប់ផ្តើមដំណើរការសវនាការ។ បញ្ហាដែលមិនទាន់បានដោះស្រាយទាំងនេះគួរតែ *ប្រសិនបើមិនត្រូវតែ* ត្រូវបានសម្រេចដោយមានសំអាងហេតុត្រឹមត្រូវ មុនពេលចាប់ផ្តើមដំណើរការនីតិវិធីលើអង្គសេចក្តី។ បញ្ហាទាំងនេះមានរៀបរាប់នៅក្នុងសំណើនេះ និងត្រូវបានរៀបចំបែងចែកដូចតទៅ៖ **ក**. យុត្តាធិការ និងច្បាប់ជាធរមាន **ខ**. ក្របខណ្ឌសម្រាប់សវនាការ **គ**. ការទទួលយកភស្តុតាង **ឃ**. សក្ខីកម្មរបស់សាក្សី និង **ង**. បញ្ហាដទៃទៀតដែលមិនទាន់ត្រូវបានដោះស្រាយ។

## I. **សេចក្តីផ្តើម**

១. ជូនកាល មេធាវីការពារក្តីបានទទួលរងការចោទប្រកាន់ថាបានប្រើយុទ្ធសាស្ត្រក្នុងការពន្យារពេល ឬបានរារាំងដល់ដំណើរការយ៉ាងមានប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធី[១]។ តាមពិតទៅ មេធាវី

---

[១] *សូមមើលជាឧទាហរណ៍* របាយការណ៍ពីសន្និសីទដែលបានរៀបចំឡើងនៅទីក្រុងភ្នំពេញពីថ្ងៃទី ២ ដល់ថ្ងៃទី ៣ ខែ មីនា ឆ្នាំ ២០០៥ ដែលបានរៀបចំឡើងដោយអង្គការ FIDH, LICADHO និង ADHOC ដែលមានចំណងជើងថា *International Criminal Court Programme: Articulation between the International Criminal Court and the Khmer Rouge Tribunal: the Place of Victims*, 3. B. David Boyle, The Legal Framework of the Khmer Rouge Tribunal, ទំព័រ ១៨, *អាចរកបាននៅគេហទំព័រ៖* http://www.vrwg.org/Publications/02/FIDHcambodge420ang.pdf “សំណួរទាំងនេះនឹងត្រូវលើកឡើងដោយមេធាវីការពារក្តី ហើយគេត្រូវដោះស្រាយឱ្យបានមុន ដើម្បីបញ្ចៀសបញ្ហាដែលថា បណ្តាមេធាវីដែលមានទេពកោសល្យនឹងធ្វើឱ្យយឺតយ៉ាវដល់សវនាការ ដែលត្រូវចំណាយពេលបីឆ្នាំក៏មិនទាន់ចប់ផង”។ *សូមមើលផងដែរ* លិខិតពីតំណាងរាស្ត្រសហរដ្ឋអាមេរិកលោក Edward R. Royce ផ្ញើជូនរដ្ឋមន្ត្រីការបរទេសសហរដ្ឋអាមេរិកលោកស្រី Hillary Rodham Clinton ទាក់ទិននឹង អ.វ.ត.ក ចុះថ្ងៃទី ២៩ ខែ មិថុនា ឆ្នាំ ២០១១ “ជនជាប់ចោទបួននាក់ ដែលពេលនោះមានអាយុចាប់ពី ៧៩ ឆ្នាំ ដល់ ៨៥ ឆ្នាំ ម្នាក់ៗបានបដិសេធមិនទទួលខុសត្រូវចំពោះការចោទប្រកាន់ពីអំពើប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មសង្គ្រាម និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ។ ពួកគេក៏បានអះអាងផងដែរថាពីការការពារខ្លួនផ្នែកច្បាប់ទៅនឹងការចោទប្រកាន់ចំពោះពួកគេ ដោយបន្ទោសអ្នកដទៃពីការរំលោភបំពាន ការធានាជាមុនពីការអនុគ្រោះទោស ហើយពួកគេថែមទាំងទាមទារថាតុលាការនេះគួរតែពិចារណាទៅលើអង្គហេតុដែលនៅក្រៅយុត្តាធិការលើពេលវេលារបស់តុលាការនេះផងដែរ (ដែលយុត្តាធិការនេះសំដៅតែទៅលើរយៈពេលនៃការគ្រប់គ្រងអំណាចរបស់ពួកខ្មែរក្រហមតែប៉ុណ្ណោះ)។ ទោះបីទឡ្ហីករណ៍ទាំងនេះមិនគួរមានឥទ្ធិពលខ្លាំងក្លាទៅលើអាណត្តិការងារ និងវិធាននីតិវិធីនៅ អ.វ.ត.ក ដោយមិននិយាយដល់ភស្តុតាងដែលបានដាក់ប្រឆាំងនឹងជនជាប់ចោទក៏ដោយ តែខ្ញុំយល់ថាទឡ្ហីករណ៍ទាំងនេះនឹងរឹតតែជួយឱ្យមានការអូសបន្លាយពេលវេលាបន្ថែមទៀត ក្នុងការនាំខ្លួនបណ្តាមេដឹកនាំនៃរបបនេះមកកាន់យុត្តិធម៌”។

ការពារក្តីស្វាគមន៍ការសេចក្តីដែលឆាប់រហ័ស និងបានស្នើសុំឲ្យមានដំណោះស្រាយសមរម្យទាន់ពេលវេលា និងស៊ីសង្វាក់ចំពោះបញ្ហាជាសារវ័ន្តនានា ដូចជា ករណីថាតើ អ.វ.ត.ក មានយុត្តាធិការទៅលើលោក អៀង សារី ឬទេ និងថាតើច្បាប់អ្វីដែលយកមកអនុវត្តដើម្បីកាត់ទោសរូបគាត់[២]។ មេធាវីការពារក្តីបានលើកឡើងម្តងហើយម្តងទៀតនូវបញ្ហាជាក់ស្តែងនានាពាក់ព័ន្ធនឹងការរៀបចំសវនាការ និងបញ្ហាផ្នែករដ្ឋបាលផ្សេងៗជូនទៅអង្គជំនុំជម្រះសាលាដំបូងទៅតាមពេលវេលាត្រឹមត្រូវ ហើយក៏បានផ្តល់ជាយោបល់ជាច្រើនក្នុងគោលបំណងដោះស្រាយបញ្ហាទាំងនេះឲ្យបានទាន់ពេលវេលាដែរ[៣]។ នៅគ្រប់ពេលវេលាទាំងអស់ មេធាវីការពារក្តីបានធ្វើការងាររបស់ខ្លួន

---

[២] អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណុំរឿង ០០២ នៅថ្ងៃទី ១៤ ខែ មករា ឆ្នាំ ២០១១។ *សូមមើល* ដីកាបង្គាប់ឲ្យដាក់សម្ភារៈឯកសារដើម្បីរៀបចំសវនាការ ចុះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១, ឯកសារលេខ E9។ បញ្ហាទាំងនេះត្រូវបានលើកឡើងជាលើកដំបូងជូនអង្គជំនុំជម្រះសាលាដំបូងនាខែ កុម្ភៈ ឆ្នាំ ២០១១។ *សូមមើល* សេចក្តីសង្ខេបអញ្ញត្រកម្មតាមវិធាន ៨៩ របស់លោក អៀង សារី និងការជូនដំណឹងនៃការមិនគោរពតាមអនុស្សរណៈក្រៅផ្លូវការនានានាពេលអនាគត ដែលត្រូវបានចេញជំនួសឲ្យសេចក្តីសម្រេចមានសំអាងហេតុរបស់តុលាការ ដែលជាកម្មវត្ថុបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារលេខ E51/4 (“សេចក្តីសង្ខេបអញ្ញត្រកម្មតាមវិធាន ៨៩ របស់លោក អៀង សារី”)។ អញ្ញត្រកម្មទាំងនេះត្រូវបានលើកឡើងជាថ្មីម្តងទៀតនៅខែ មេសា ឆ្នាំ ២០១១ តាមរយៈ ការបង្ហាញពីបញ្ហាផ្នែកច្បាប់របស់លោក អៀង សារី ដែលគាត់មានបំណងលើកឡើងក្នុងសវនាការបឋម ចុះថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ២០១១, ឯកសារលេខ E9/23 និងនាពេលថ្មីៗនេះជាកម្មវត្ថុនៃលិខិតផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដោយរួមទាំងលិខិតរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា៖ “បញ្ហានានាដែលបង្កជាឧបសគ្គដល់ប្រសិទ្ធភាពនៃដំណាក់ដំបូងនៃសវនាការបឋម” ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១១ និង លិខិតរបស់ក្រុមមេធាវីការពារក្តីផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា៖ “សំណើសុំទទួលព័ត៌មានទាក់ទិននឹងអញ្ញត្រកម្មដែលនៅសេសសល់មិនទាន់បានដោះស្រាយ” ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១។

[៣] *សូមមើលជាឧទាហរណ៍* លិខិតរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា៖ “ការកំណត់កាលបរិច្ឆេទនៃសវនាការលើអង្គសេចក្តី” ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១; លិខិតរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា៖ “សំណើសុំការបញ្ជាក់ពីអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា “បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង, ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5” ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១១; លិខិតរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា៖ “បញ្ហានានាដែលបង្កជាឧបសគ្គដល់ប្រសិទ្ធភាពនៃដំណាក់ដំបូងនៃសវនាការបឋម” ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១១; លិខិតរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា៖ “សំណើសុំការបញ្ជាក់ទាក់ទិននឹងអញ្ញត្រកម្មចំពោះបញ្ជីឯកសារ

ប្រកបដោយសុចរិត ដើម្បីឲ្យកិច្ចដំណើរការនីតិវិធីបានដំណើរការទៅមុខទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព និងមានតម្លាភាព ឲ្យបានច្រើនអាចធ្វើទៅបាន។

២. អង្គជំនុំជម្រះសាលាដំបូងបានបង្ហាញពីចេតនាក្នុងការចាប់ផ្ដើមកិច្ចដំណើរការនីតិវិធីលើអង្គសេចក្ដីក្នុងឆ្នាំ ២០១១[៤] ដោយសារតែមានសម្ពាធពីម្ចាស់ជំនួយរបស់ អ.វ.ត.ក។ បើទោះជាមានចេតនានេះក្ដី អង្គជំនុំជម្រះសាលាដំបូងមិនទំនងជាអាចចាប់ផ្ដើមកិច្ចដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាពនាពេលនេះទេ ជាពិសេស ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងបន្តចាត់ទុកខ្លួនជា "តុលាការគំរូ" ដែលក្នុងនោះមានការគោរពសិទ្ធិជាសារវ័ន្តរបស់ជនជាប់ចោទ ដោយអង្គជំនុំជម្រះត្រូវតែធានាឲ្យមានកិច្ចដំណើរការនីតិវិធីត្រឹមត្រូវ និងយុត្តិធម៌សម្រាប់គ្រប់ភាគីពាក់ព័ន្ធដែរ។

៣. ដោយសារតែការប្រញាប់ប្រញាល់ចាប់ផ្ដើមកិច្ចដំណើរការនីតិវិធីសវនាការនោះ អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានដោះស្រាយបញ្ហាអង្គច្បាប់ និងនីតិវិធីជាច្រើន ដោយទុកបញ្ហាទាំងនោះចោលដោយគ្មានដំណោះស្រាយ ឬមានភាពមិនច្បាស់លាស់ ទោះបីគេមើលឃើញគ្រប់ទិដ្ឋភាពទាំងអស់ថា អង្គជំនុំជម្រះសាលាដំបូងមានពេលវេលាគ្រប់គ្រាន់ក្នុងការពិចារណា និងចេញសេចក្ដីសម្រេចដោយមានសំអាងហេតុគ្រប់គ្រាន់ក៏ដោយ។ ការចាប់ផ្ដើមដំណើរការសវនាការដោយមិនបានដោះស្រាយបញ្ហាទាំងនេះ យ៉ាងហោចណាស់ក៏ធ្វើឲ្យកិច្ចដំណើរការនីតិវិធីនោះមិនមានរបៀបរៀបរយ មិនមានប្រសិទ្ធភាព និងដែលធ្ងន់ធ្ងរជាងគេនោះគឺ មិនមានភាពយុត្តិធម៌។

---

របស់ ក.ស.ព និងដើមបណ្ដឹងរដ្ឋប្បវេណី" ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១១; លិខិតរបស់ក្រុមមេធាវីការពារក្ដីលោក អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា៖ "កំណត់សម្គាល់ទាក់ទិននឹងការជំទាស់របស់លោក អៀង សារី ទៅនឹងឯកសាររបស់ ក.ស.ព និងដើមបណ្ដឹងរដ្ឋប្បវេណីសម្រាប់រយៈពេលបីសប្ដាហ៍ដំបូងនៃសវនាការ" ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១; លិខិតរបស់ក្រុមមេធាវីការពារក្ដីលោក អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា៖ "សំណើសុំព័ត៌មានទាក់ទិននឹងអញ្ញត្រកម្មនានាដែលនៅសេសសល់មិនទាន់បានដោះស្រាយ" ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១"។

[៤] *សូមមើល* សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យពិចារណាឡើងវិញអំពីលក្ខខណ្ឌនានានៃដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធីរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១, ឯកសារលេខ E124/2, កថាខណ្ឌ ៦, ១២។

៤. មេធាវីការពារក្តី និងតាមពិតទៅភាគីភាគច្រើនទៀត បានលើកសំណើម្តងហើយម្តងទៀតនៅក្នុងកិច្ចប្រជុំរៀបចំសវនាការ[៥] តែកន្លងមកសំណើទាំងនេះពុំត្រូវបានគេយកចិត្តទុកដាក់ទាល់តែសោះ។ បញ្ហាជាច្រើន ប្រសិនបើមិនមែនទាំងអស់ទេនោះ ក្នុងចំណោមបញ្ហាដែលលើកឡើងខាងក្រោម ធ្លាប់ត្រូវបានលើកឡើងម្តងហើយម្តងទៀត តាមរយៈលិខិតនានាផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង[៦] ដូចដែលបានស្នើឡើងដោយអង្គជំនុំជម្រះសាលាដំបូង[៧]។ វាបង្ហាញឲ្យ

---

[៥] *សូមមើល* លិខិតរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា៖ “ការកំណត់កាលបរិច្ឆេទនៃសវនាការលើអង្គសេចក្តី” ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១; លិខិតរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា៖ “សំណើសុំការបញ្ជាក់ពីអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា “បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង, ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5” ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១១; សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឲ្យមានការប្រជុំមួយស្តីពីការរៀបចំសវនាការ និងការប្រជុំទៀងទាត់នានាស្តីពីស្ថានភាពសវនាការសម្រាប់សំណុំរឿង ០០២ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ២០១១, ឯកសារលេខ E132/1; សំណើរបស់របស់ដើមបណ្តឹងរដ្ឋប្បវេណី ស្នើសុំឲ្យមានកិច្ចប្រជុំរៀបចំសវនាការ និងការប្រជុំទៀងទាត់ស្តីពីស្ថានភាពសវនាការសម្រាប់សំណុំរឿង ០០២ និង ស្នើសុំការបញ្ជាក់ស្តីពីការកំណត់ពេលវេលា និងការរៀបចំសវនាការ ចុះថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១, ឯកសារលេខ E132/2; ការជំទាស់ សេចក្តីសង្ខេប និងសេចក្តីជូនដំណឹង [របស់លោក នួន ជា] ទាក់ទិននឹងឯកសារនានាជាច្រើនដែលនឹងត្រូវដាក់ជូនអង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E131/1/9។

[៦] *សូមមើល* លិខិតរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា៖ “ការកំណត់កាលបរិច្ឆេទនៃសវនាការលើអង្គសេចក្តី” ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១; លិខិតរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា៖ “សំណើសុំការបញ្ជាក់ពីអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូងដែលមានចំណងជើងថា “បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង, ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5” ចុះថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១១; លិខិតរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា៖ “បញ្ហានានាដែលបង្កជាឧបសគ្គដល់ប្រសិទ្ធភាពនៃដំណាក់ដំបូងនៃសវនាការបឋម” ចុះថ្ងៃទី ១ ខែ វិច្ឆិកា ឆ្នាំ ២០១១; លិខិតរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា៖ “សំណើសុំការបញ្ជាក់ទាក់ទិននឹងអញ្ញត្រកម្មចំពោះបញ្ជីឯកសាររបស់ ក.ស.ព និងដើមបណ្តឹងរដ្ឋប្បវេណី” ចុះថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០១១; លិខិតរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា៖ “កំណត់សម្គាល់ទាក់ទិននឹងការជំទាស់របស់លោក អៀង សារី ទៅនឹងឯកសាររបស់ ក.ស.ព និងដើមបណ្តឹងរដ្ឋប្បវេណីសម្រាប់រយៈពេលបីសប្តាហ៍ដំបូងនៃ

ឃើញកាន់តែច្បាស់ថា លិខិតក្រៅផ្លូវការទាំងនេះពុំមានអានុភាពអ្វីទាំងអស់ ដែលជាផ្នែកមួយដែលនាំឲ្យពុំមានតម្លាភាពដែលធ្វើឲ្យតុលាការនេះត្រូវបានគេរិះគន់ជាញឹកញយនោះ[៨]។ សំណើជា

---

សវនាការ" ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១; លិខិតរបស់ក្រុមមេធាវីការពារក្តីលោក អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើងថា៖ "សំណើសុំព័ត៌មានទាក់ទិននឹងអញ្ញត្រកម្មនានាដែលនៅសេសសល់មិនទាន់បានដោះស្រាយ" ចុះថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១"។

[៧] *សូមមើល* ប្រតិចារឹក ចុះថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១, ទំព័រ ១០៖ "ប្រសិនបើអាចធ្វើទៅបាន ភាគីនានាត្រូវបានជំរុញឲ្យលើកឡើងអំពីការព្រួយបារម្ភ ឬស្នើសុំព័ត៌មានជាលក្ខណៈក្រៅផ្លូវការទៅមន្ត្រីច្បាប់ជាន់ខ្ពស់របស់អង្គជំនុំជម្រះសាលាដំបូងបាន។ ក្នុងកម្រិតដែលអាចធ្វើទៅបាន និងសមស្រប វិធីនេះគួរតែយកមកប្រើប្រាស់ជំនួសឲ្យការដាក់សំណើសុំដែលគ្រាន់តែធ្វើការស្វែងរកព័ត៌មាន ឬលើកជាសំណួរនោះ"។ *សូមមើលផងដែរ* សារអេឡិចត្រូនិករបស់មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង Susan Lamb ផ្ញើជូនភាគី លិខិតទាក់ទងទៅភាគីក្នុងសំណុំរឿង ០០២ ទាក់ទិននឹងការកំណត់កាលបរិច្ឆេទនៃការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ និងសវនាការលើអង្គសេចក្តីក្នុងសំណុំរឿង ០០២ និងព័ត៌មាននានាមុនពេលសវនាការពីថ្ងៃទី ១៩ ដល់ថ្ងៃទី ២០ ខែ តុលា ឆ្នាំ ២០១១ ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១ ("សារអេឡិចត្រូនិកស្តីពីការកំណត់កាលបរិច្ឆេទ")៖ "ភាគីត្រូវបានជំរុញឲ្យលើកឡើងជាលក្ខណៈក្រៅផ្លូវការនូវបញ្ហាអង្គច្បាប់នានាដែលនៅសេសសល់ដែលពួកគេយល់ថា អាចនឹងជាឧបសគ្គដល់ប្រសិទ្ធភាពនៃដំណាក់កាលដំបូងនៃសវនាការលើអង្គសេចក្តីទៅមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងបាន ...។" សារអេឡិចត្រូនិករបស់ មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូងផ្ញើជូន ក.ស.ព ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១៖ "សហព្រះរាជអាជ្ញាត្រូវបានស្នើសុំឲ្យដកឈ្មោះចៅក្រមចេញពីលិខិតឆ្លើយឆ្លងប្រភេទនេះនាពេលអនាគត ដែលវាជាការរំលោភបំពានដល់សេចក្តីណែនាំពីមុនៗដែលបានផ្សព្វផ្សាយដល់ភាគីនានា"។

[៨] *សូមមើលជាឧទាហរណ៍* អនុសាសន៍នានាទាក់ទិននឹងតម្លាភាពបន្ថែមទៀតនៅអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) ដែលបានដាក់ជូនដោយសមាជិកសង្គមស៊ីវិល និងសមាជិកបណ្តាញសារព័ត៌មានកម្ពុជា ចុះថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៨, *អាចរកបាននៅគេហទំព័រ* http://www.cambodiatribunal.org/CTM/Recommendations%20Regarding%20Additional%20Transparency.pdf?phpMyAdmin=8319ad34ce0db941ff04d8c788f6365e៖ "អ.វ.ត.ក ត្រូវបានបង្កើតឡើងជាគំរូសម្រាប់កំណែទម្រង់ប្រព័ន្ធច្បាប់ និងយុត្តិធម៌នៅកម្ពុជា ហេតុនេះ អ.វ.ត.ក មិនគួរក្លាយជាគំរូនៃការកំហិតមិនចាំបាច់ទៅលើការបញ្ចេញមតិដោយសេរី និងការទទួលបានព័ត៌មាននោះទេ"។ *សូមមើលផងដែរ* Holly Telerant & Pen Rany, *Must Justice be Seen to be Done? Public Scrutiny and Participation in the KRT*, VOICE OF JUSTICE RESEARCH BULLETIN, Year 14, Issue 136, ខែ មីនា-មេសា ឆ្នាំ ២០០៧, ទំព័រ ១៥-១៨៖ "សាលាក្តីខ្មែរក្រហមត្រូវបានបង្កើតឡើងសម្រាប់ប្រជាជនកម្ពុជាសម្រាប់ហេតុផលផ្សេងៗដែលមានការពិចារណាយ៉ាងត្រឹមត្រូវ។ តុលាការនេះមិនត្រឹមតែត្រូវបានបង្កើតឡើងដើម្បីនាំខ្លួនចារីមកកាន់យុត្តិធម៌ប៉ុណ្ណោះទេ តែគឺបង្កើតឡើងដើម្បីឲ្យទទួលបានយុត្តិធម៌យ៉ាងពិតប្រាកដ។ តុលាការនេះត្រូវបានបង្កើតឡើងដើម្បីបង្កើតជាកំណត់ហេតុប្រវត្តិសាស្ត្រឲ្យបានត្រឹមត្រូវ ដើម្បីដាស់ស្មារតីឲ្យមានការពិភាក្សាគ្នានៅទូទាំងប្រទេស និងដើម្បីចាប់ផ្តើមឲ្យមានការផ្សះផ្សារជាតិដែលបានអូសបន្លាយពេលជាយូរមកហើយ។ វាមានការលំបាកក្នុងការសម្រេចឲ្យបានតាមគោលដៅទាំងនេះ ប្រសិនបើដំណើរការមុនសវនាការត្រូវបានធ្វើឡើងជាលក្ខណៈឯកជនទាំងស្រុង

ផ្លូវការនេះប្រហែលនឹងមានអានុភាពវិជ្ជមាន។

## II. សំណើ

៥. មេធាវីការពារក្តីសូមស្នើថា បញ្ហាទាំងអស់ខាងក្រោមនេះត្រូវតែដោះស្រាយឲ្យបានពេញលេញមុននឹងចាប់ផ្តើមដំណើការសវនាការលើអង្គសេចក្តី។ បញ្ហាមួយចំនួនតូចទាំងនេះអាចមិនពាក់ព័ន្ធដោយផ្ទាល់ទៅនឹង “សវនាការតូចៗ” ឬ “ផ្នែកតូចៗ” ក្នុងដំណាក់កាលដំបូងនេះទេ[៥]។ ទោះជាយ៉ាងណាក្តី ដោយសារវិសាលភាពនៃសវនាការក្នុងដំណាក់កាលដំបូងនេះពុំមានភាពច្បាស់លាស់

---

នោះ”។ Long Panhavuth, *More Transparency Needed at Khmer Rouge Tribunal*, Cambodian Journalism Review, ថ្ងៃទី ១៨ ខែ មេសា ឆ្នាំ ២០០៨, *អាចរកបាននៅគេហទំព័រ http://cjrenglish.wordpress.com/2008/04/18/more-transparency-needed-at-eccc/*៖ “សាធារណជនមានការនឿយណាយនឹងព័ត៍មានមួយចំនួនដែលតុលាការនេះលាក់បាំងចំពោះការងាររបស់ខ្លួន។ ការអនុវត្តនូវភាពសម្ងាត់ចំពោះការងារមួយចំនួនធំនាពេលបច្ចុប្បន្ននៅ អ.វ.ត.ក បានបន្ថយបង្អាក់នូវការចូលរួមរបស់សាធារណជន និងបានកាត់បន្ថយនូវភាពជឿជាក់បាននៃដំណើរការការងារនៅតុលាការនេះ។ តុលាការនេះក៏ចាំបាច់ត្រូវបង្ហាញពីតម្លាភាព និងបង្កើនការចូលរួម និងការពិភាក្សាជាមួយបណ្តាអង្គការក្រៅរដ្ឋាភិបាល និងបណ្តាញសារព័ត៍មាននានាឡើងវិញ”; *Joint Statement of NGOs: Concern about the Restrictions on Transparency Resulting from the Co-Investigating Judges Order on Breach of Confidentiality*, ថ្ងៃទី ៦ ខែ មីនា ឆ្នាំ ២០០៩, ឯកសារលេខ D138/1/1.9៖ “តម្លាភាពគឺជាលក្ខខណ្ឌសំខាន់មួយរបស់ស្ថាប័នសាធារណៈទាំងអស់ រួមទាំងស្ថាប័នតុលាការផងដែរ គឺជាមូលដ្ឋានដើម្បីទទួលបានការទុកចិត្តពីសាធារណជន និងជាការការពារខ្លួនប្រឆាំងនឹងអំពើពុករលួយ និងការជ្រៀតជ្រែកផ្នែកនយោបាយមិនត្រឹមត្រូវ។ ភាពសម្ងាត់ និងការរក្សាការសម្ងាត់នៃផ្នែកខ្លះនៃកិច្ចដំណើរការនីតិវិធីរបស់តុលាការជាការចាំបាច់ ...។ ទោះជាយ៉ាងណាក្តី គោលនយោបាយស្តីពីភាពសម្ងាត់ត្រូវតែថ្លឹងថ្លែងជាមួយនឹងតម្លាភាពដ៏សំខាន់របស់ស្ថាប័ន និងគោលដៅ និងកាលៈទេសៈពិសេសរបស់ អ.វ.ត.ក”។

[៥] នៅក្នុងដីកាសម្រេចបំបែកដំណើរការនីតិវិធី អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា អង្គជំនុំជម្រះនឹងផ្អាកចេញសេចក្តីសម្រេចលើ៖ ផ្នែកនានានៃញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយ ដោយសារកំហុសនីតិវិធី ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១, ឯកសារលេខ E58; សំណើរបស់ អៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងចុះពិនិត្យដល់ទីកន្លែង ចុះថ្ងៃទី ៣១ ខែ សីហា ឆ្នាំ ២០១១, ឯកសារលេខ E113; និង សំណើរបស់សហព្រះរាជអាជ្ញា សុំឲ្យអង្គជំនុំជម្រះសាលាដំបូង។ កំណត់បទចោទសាជាថ្មី ទាក់ទងនឹងអង្គហេតុនៃអំពើរំលោភសេពសន្ថវៈ ថាជាបទរំលោភសេពសន្ថវៈនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ជាជាងថាជាអំពីអមនុស្សធម៌ផ្សេងៗទៀតនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ចុះថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១១, ឯកសារលេខ E99 នៅពេលដែលអង្គជំនុំជម្រះសម្រេចថា សំណើទាំងនេះមិនទាក់ទិននឹងសវនាការដំបូងទេ។

និងអាចពន្រ្យាកនៅពេលណាមួយនោះ[10] បញ្ហាទាំងអស់ខាងក្រោមទាមទារឲ្យមានដំណោះស្រាយភ្លាមៗ។ បញ្ហានានាទាំងឡាយណាដែលបានលើកឡើងជាអញ្ញត្រកម្ម ដែលអង្គជំនុំជម្រះសាលាដំបូងអាចពិចារណាថាពុំមានលក្ខណៈជាផ្នែកយុត្តាធិការនោះ គួរត្រូវបានសម្រេចដោយអង្គជំនុំជម្រះសាលាដំបូង មុនពេលចាប់ផ្តើមដំណើរការសវនាការ តាមរយៈអំណាចជាប់មកជាមួយរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការសម្រេចពីវិសាលភាពនៃច្បាប់ជាធរមាន[11]។

## ក. ការសម្រេចស្តាពរអំពីយុត្តាធិការរបស់ អ.វ.ត.ក និង ច្បាប់ជាធរមាន

៦. អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានសម្រេចស្តាពរអំពីយុត្តាធិការរបស់ អ.វ.ត.ក ទៅលើលោក អៀង សារី ដោយសារគាត់បានទទួលព្រះរាជក្រឹត្យលើកលែងទោស និងអនុគ្រោះទោស និងគោលការណ៍*គ្មានការកាត់ទោសពីរដងលើរឿងក្តីតែមួយ* (*ne bis in idem*) នៅឡើយទេ។ លោក អៀង សារី មិនគួរត្រូវបានយកមកកាត់ទោសទេ ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលសម្រេចជាចុងក្រោយថា អ.វ.ត.ក ពុំមានយុត្តាធិការទៅលើរូបគាត់នោះ។ ដើម្បីធានាថា សិទ្ធិរបស់លោក អៀង សារី មិនត្រូវបានគេរំលោភនោះ មេធាវីការពារក្តីបានស្នើឲ្យអង្គជំនុំជម្រះសាលាដំបូងផ្អាកកិច្ចដំណើរការនីតិវិធីសិន រហូតដល់ពេលបញ្ហានេះត្រូវបានដោះស្រាយយ៉ាងពេញលេញជាមុនសិន ដោយសារបញ្ហាយុត្តាធិការនេះគឺជាបញ្ហាអង្គច្បាប់ដែលត្រូវសម្រេច[12]។ វានឹងមានភាពអយុត្តិធម៌ជាមូលដ្ឋានក្នុងការកាត់ទោសលោក អៀង សារី ប្រសិនបើព្រះរាជក្រឹត្យអនុគ្រោះទោសដល់រូបគាត់ ឬគោលការណ៍*គ្មានការកាត់ទោសពីរដងលើរឿងក្តីតែមួយ* (*ne bis in idem*) រារាំងមិនឲ្យមានការកាត់ទោសរូបគាត់នោះ។ អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានសម្រេចសេចក្តីទៅលើសំណើសុំផ្អាកនៅឡើយទេ ទោះបីតាមសភាពជាក់ស្តែងនោះគឺថា សេចក្តីសន្និដ្ឋានចោទប្រកាន់

---

[10] *សូមមើល* ដីកាសម្រេចបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩*ស្ទួនពីរ* នៃវិធានផ្ទៃក្នុង ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១, ឯកសារលេខ E124, កថាខណ្ឌ ៦។

[11] *សូមមើលជាឧទាហរណ៍* សេចក្តីសម្រេចលើភាពអាចអនុវត្តបាននូវសហឧក្រិដ្ឋកម្មរួម ចុះថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ ២០១១, ឯកសារលេខ E100/6, កថាខណ្ឌ ២៤-២៥។

[12] សំណើរបស់ អៀង សារី សុំផ្អាកការចាប់ផ្តើមដំណើរការនីតិវិធីជំនុំជម្រះក្តីរហូតដល់មានការសម្រេចជាស្តាពរលើបណ្តឹងអញ្ញត្រកម្មរបស់ អៀង សារី ទាក់ទងនឹងព្រះរាជអនុគ្រោះទោស និងលើកលែងទោស និងគោលការណ៍មិនកាត់ទោសពីរដងចំពោះបទល្មើសតែមួយ (*Ne Bis in Idem*) ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E135។

នឹងត្រូវចាប់ផ្ដើមនៅសប្ដាហ៍ក្រោយរួចហើយ។

៧. អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានសម្រេចស្ថាពរនៅឡើយទេចំពោះករណី ថាតើទំនាក់ទំនងជាមួយជម្លោះប្រដាប់អាវុធអន្តរជាតិ គឺជាធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អ.វ.ត.ក ឬទេ។ ប្រសិនបើការសម្រេចនេះពុំទាន់ត្រូវបានអង្គជំនុំជម្រះតុលាការកំពូលសម្រេចឱ្យបានមុនពេលចាប់ផ្ដើមសវនាការនោះ ភាគីនឹងមិនបានដឹងថាតើពួកគេត្រូវបង្ហាញភ័ស្ដុតាងទាក់ទិននឹងចំណងទាក់ទងរវាងអំពើនានាដែលត្រូវបានចោទប្រកាន់ថាជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងជម្លោះប្រដាប់អាវុធអន្តរជាតិ ក្នុងអំឡុងពេលដំណាក់កាលដំបូងនៃសវនាការនេះឬយ៉ាងណាទេ។ ដើម្បីការពារសិទ្ធិរបស់លោក អៀង សារី មេធាវីការពារក្ដីបានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូងផ្អាកកិច្ចដំណើរការនីតិវិធី រហូតទាល់តែបញ្ហានេះត្រូវបានដោះស្រាយស្ថាពរជាមុនសិន[១៣]។ សំណើនេះជាសំណើចាំបាច់ក្នុងការធានាថា រាល់សាក្សីដែលនឹងត្រូវកោះហៅពីពេលនេះរហូតដល់ពេលដែលដំណោះស្រាយពេញលេញលើបញ្ហានៃលក្ខខណ្ឌតម្រូវនៃទំនាក់ទំនង អាចមកផ្ដល់សក្ខីកម្មទៅលើបញ្ហាថាតើជម្លោះប្រដាប់អាវុធពិតជាបានកើតមានឬទេ ក្នុងអំឡុងយុត្តាធិការលើពេលវេលានៃដីកាដំណោះស្រាយ និងថាតើអំពើនានាដែលត្រូវបានចោទប្រកាន់ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិមានទំនាក់ទំនងយ៉ាងពេញលេញជាមួយនឹងជម្លោះប្រដាប់អាវុធឬទេ។ ការផ្អាកកិច្ចដំណើរការនីតិវិធីជាការសំខាន់ក្នុងការធានាថា ប្រសិនបើអង្គជំនុំជម្រះតុលាការកំពូលសម្រេចច្រានចោលសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង និងសម្រេចតម្កល់សេចក្ដីសេចក្ដីសម្រេចរបស់អង្គបុរេជំនុំជម្រះនោះ គេពុំចាំបាច់កោះហៅសាក្សីទាំងនេះមកផ្ដល់សក្ខីកម្មចំពោះបញ្ហាដោយឡែកនេះទេ។ អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានសម្រេចលើការផ្អាកនេះទេ ទោះបីការពិតគឺថា សេចក្ដីសន្និដ្ឋានចោទប្រកាន់នឹងត្រូវចាប់ផ្ដើមដំណើរការនាសប្ដាហ៍ក្រោយក៏ដោយ។

៨. អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានសម្រេចស្ថាពរនៅឡើយទេចំពោះករណី ថាតើ អ.វ.ត.ក អាចអនុវត្តបទឧក្រិដ្ឋអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវអន្តរជាតិបានឬទេ ទោះបីការពិតគឺ

---

[១៣] សំណើរបស់លោក អៀង សារី សុំផ្អាកការអនុវត្ត "សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាសុំដកលក្ខខណ្ឌតម្រូវស្ដីពីទំនាក់ទំនងនៃជម្លោះប្រដាប់អាវុធ ចេញពីនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" ចុះថ្ងៃទី ២ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E134។

ថា បទឧក្រិដ្ឋ និងទម្រង់នៃការទទួលខុសត្រូវទាំងនោះ មិនទាន់មានចែងនៅក្នុងច្បាប់កម្ពុជា ជាធរមាននៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះ[១៤]។ ប្រសិនបើ អ.វ.ត.ក មិនអាចអនុវត្ត បទឧក្រិដ្ឋអន្តរជាតិ និងទម្រង់នៃការទទួលខុសត្រូវនោះ តុលាការនេះនឹងមិនមានយុត្តាធិការក្នុងការ កាត់ទោសលោក អៀង សារី ទេ ដោយសារថាបទឧក្រិដ្ឋតាមច្បាប់ជាតិដែលលោក អៀង សារី ត្រូវបានចោទប្រកាន់នោះ ត្រូវបានរកឃើញថាមិនមានសុពលភាពទេ[១៥]។

៩. អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានសម្រេចស្ថាពរនៅឡើយទេចំពោះករណី ថាតើ អ.វ.ត.ក មានយុត្តាធិការក្នុងការអនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើឬទេ ហើយប្រសិនបើអាចអនុវត្តបាន នោះ តើទម្រង់នៃការទទួលខុសត្រូវនេះមានទំហំប៉ុណ្ណាដែរ[១៦]។ ប្រសិនបើ អ.វ.ត.ក អាចនឹង អនុវត្តការទទួលខុសត្រូវរបស់ថ្នាក់លើមែននោះ គេនៅពុំទាន់ដឹងច្បាស់ថាតើ៖

ក. វាអាចត្រូវបានយកទៅអនុវត្តត្រឹមតែក្នុងស្ថានភាពដែលពាក់ព័ន្ធនឹងជម្លោះប្រដាប់អាវុធ អន្តរជាតិ ឬទេ?

ខ. វាអាចត្រូវបានយកទៅអនុវត្តត្រឹមតែចំពោះថ្នាក់លើក្នុងផ្នែកយោធា ឬទេ?

គ. វាអាចអនុវត្តនៅពេលមានទំនាក់ទំនងហេតុ និងផលរវាងអំពើរបស់ថ្នាក់លើ និងឧក្រិដ្ឋកម្ម ដែលអ្នកក្រោមបង្គាប់របស់ខ្លួន និងនៅពេលដែលឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងសកម្មភាពនានាដែល ថ្នាក់លើមានតួនាទីតាមច្បាប់ជាមុន ក្នុងការទប់ស្កាត់ ឬដាក់ទណ្ឌកម្ម ឬទេ? ឬ

ឃ. វាអាចត្រូវបានយកទៅអនុវត្តចំពោះឧក្រិដ្ឋកម្មដែលមានចេតនាពិសេស ឬទេ?

---

[១៤] *សូមមើល* សេចក្តីសង្ខេបអញ្ញត្រកម្មតាមវិធាន ៨៩ របស់លោក អៀង សារី, កថាខណ្ឌ ២៥។

[១៥] សេចក្តីសម្រេចលើអញ្ញត្រកម្មនានារបស់មេធាវីការពារក្តី (អាជ្ញាយុកាលនៃបទឧក្រិដ្ឋតាមច្បាប់ជាតិ), ឯកសារលេខ E122, ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ២០១១។

[១៦] *សូមមើល* សេចក្តីសង្ខេបអញ្ញត្រកម្មតាមវិធាន ៨៩ របស់លោក អៀង សារី, កថាខណ្ឌ ២៦។

១០. <u>ប្រសិនបើ អ.វ.ត.ក អាចអនុវត្តឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិបាន ទោះបីជាការពិតគឺថា ឧក្រិដ្ឋកម្មទាំងនេះពុំមាននៅក្នុងច្បាប់កម្ពុជាជាធរមាននៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ក៏ដោយនោះ អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានសម្រេចស្ថាពរនៅឡើយទេចំពោះករណី៖</u>

ក. តើរដ្ឋមួយ ឬគោលនយោបាយអង្គការណាមួយ គឺជាធាតុផ្សំទូទៅមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិឬទេ ដូចជា៖ **១.**ដោយសារវាមាននៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ និង/ឬ **២.**អនុលោមតាមគោលការណ៍*ភាពទន់ភ្លន់នៃច្បាប់ (lex mitior)*?

ខ. តើគោលការណ៍នីត្យានុកូលភាពភ្ជាប់ជាមួយនឹងប្រភេទទាំងមូលនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" តែមិនភ្ជាប់ជាមួយនឹងប្រភេទតូចៗនៃអំពើទាំងនោះឬទេ?

គ. តើគោលការណ៍ *មិនមែនជាបទល្មើសបើគ្មានច្បាប់ចែងជាលាយលក្ខណ៍អក្សរ (nullum crimen sine lege scripta)* ត្រូវបានការពារដោយការអនុវត្ត "អំពើអមនុស្សធម៌ផ្សេងៗទៀត" ឬទេ?

ឃ. តើ "ការជម្លៀសដោយបង្ខំ" គឺជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ឬទេ (ប្រសិនបើ "អំពើអមនុស្សធម៌ផ្សេងៗទៀត" អាចយកមកអនុវត្តបាន ហើយគោលការណ៍នីត្យានុកូលភាពភ្ជាប់ជាមួយនឹងប្រភេទតូចៗនៃអំពីទាំងនោះ)?

ង. តើ "ការបាត់ខ្លួនដោយបង្ខំ" គឺជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ឬទេ (ប្រសិនបើ "អំពើអមនុស្សធម៌ផ្សេងៗទៀត" អាចយកមកអនុវត្តបាន ហើយគោលការណ៍នីត្យានុកូលភាពភ្ជាប់ជាមួយនឹងប្រភេទតូចៗនៃអំពីទាំងនោះ)?

ច. តើធាតុផ្សំសំខាន់ៗ និងនិយមន័យដែលអាចអនុវត្តនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពីបទមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទុក្ខបុកម្នេញដោយសារមូលហេតុសាសនា និងពូជសាសន៍ និង (ប្រសិនបើអាច) "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដោយរួមមាន ការវាយប្រហារទៅលើភាពថ្លៃថ្នូរជាមនុស្ស ការជម្លៀសដោយបង្ខំ និងការបាត់ខ្លួនដោយបង្ខំ មានអ្វីខ្លះ?

ឆ. តើលក្ខណៈរើសអើងនៃ "ការវាយប្រហារ" ណាមួយ នឹងត្រូវបានវាយតម្លៃដោយផ្អែកទៅលើកត្តាអត្តនោម័តរបស់ជនជាប់ចោទ ឬលើកត្តាសត្យានុម័ត?

ជ. តើចេតនាពិសេសដែលជាធាតុផ្សំមួយនៃការធ្វើទុក្ខបុកម្នេញ នឹងត្រូវបានវាយតម្លៃដោយផ្អែកលើកត្តាអត្តនោម័តរបស់ជនជាប់ចោទ ឬលើកត្តាសត្យានុម័ត?

ឈ. នៅពេលដែលនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនាពេលបច្ចុប្បន្ន និងតាមលក្ខន្តិកៈតុលាការ ICC ផ្តល់ប្រយោជន៍ដល់ជនជាប់ចោទជាងនិយមន័យតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ នោះ អញ្ចឹងបើតាមគោលការណ៍ *ភាពទន់ភ្លន់នៃច្បាប់* (*lex mitior*) តើនិយមន័យនាពេលបច្ចុប្បន្ន ឬនិយមន័យនៅតុលាការ ICC ត្រូវតែយកមកអនុវត្តឬទេ?

ញ. តើឯកសារសំអាងផ្លូវច្បាប់នានាដែលយកមកសំអាងក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅក្នុងដីកាដំណោះស្រាយនោះ រំលោភទៅលើការហាមប្រាមទៅលើការប្រៀបធៀប (analogy) ទាំងក្នុងប្រព័ន្ធច្បាប់ស៊ីវិល និងនៅក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិឬទេ?

ដ. តើ៖ **១.**កាតព្វកិច្ចក្នុងការរស់នៅក្នុងសហករណ៍ដែលនាំឱ្យមានការដកហូតទ្រព្យសម្បត្តិទាំងអស់ **២.**ការលុបបំបាត់កម្មសិទ្ធិឯកជន **៣.**ការផ្លាស់ប្តូរស្ថាប័នសេដ្ឋកិច្ច រដ្ឋបាល និងនយោបាយដោយរចនាសម្ព័ន្ធកាន់អំណាចរបស់ពួកបដិវត្តន៍ និង **៤.**ការបោះបង់ចោលគោលការណ៍ជាមូលដ្ឋានដែលគ្រប់គ្រងផ្នែកយុត្តិធម៌ក្នុងរឿងព្រហ្មទណ្ឌ ដោយយកការគ្រប់

គ្រងនយោបាយបែបប្រព័ន្ធប្រមូលផ្តុំអំណាចមកថ្នាក់មជ្ឈិម អាចត្រូវបានចាត់ទុកថាជាអង្គហេតុដែលមានតម្លៃជាភ័ស្តុតាងពី "ការវាយប្រហារ" តាមនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬទេ?

ឋ. តើ បុគ្គលិកយោធា និងសន្តិសុខ ដោយរួមទាំងអ្នកដែលបាត់បង់សមត្ថភាពក្នុងការប្រយុទ្ធ *(hors de combat)* អាចត្រូវបានចាត់ទុកថាជា "ប្រជាជនស៊ីវិល" ឬទេ?

ឌ. តើ អំពើហិង្សាដែលពួកយោធា (រួមទាំងអ្នកដែលបាត់បង់សមត្ថភាពក្នុងការប្រយុទ្ធ *(hors de combat)* ផង) គឺជាគោលដៅចំបងនៃការវាយប្រហារ បង្កើតជាភ័ស្តុតាងពី "ការវាយប្រហារ" ដែលជាធាតុផ្សំទូទៅមួយនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ អ.វ.ត.ក ឬទេ?

ឍ. តើនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ច្បាប់ទំនៀមទម្លាប់អន្តរជាតិបានបញ្ចូលនូវលក្ខខណ្ឌចេតនានៃការរើសអើងទៅក្នុងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ឬទេ?

ណ. តើធាតុផ្សំសំខាន់ៗ និងនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិពីបទ៖ ការដាក់ឱ្យទៅជាទាសករ អំពើទារុណកម្ម (ប្រសិនបើមាន) ការរំលោភសេពសន្ថវៈ (ប្រសិនបើមាន) និងការរៀបការដោយបង្ខំ (ប្រសិនបើមាន) មានអ្វីខ្លះ?

ត. តើ "ការដាក់ក្នុងមន្ទីរឃុំឃាំង" គឺជាអំពើជាមូលដ្ឋានដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ឬទេ?

ថ. តើ "អំពើទារុណកម្ម" គឺជាអំពើជាមូលដ្ឋានដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ឬទេ?

ទ. តើ "ការរំលោភសេពសន្ថវៈ" គឺជាអំពើជាមូលដ្ឋានដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ឬទេ?

ធ. តើ "ការរៀបការដោយបង្ខំ" ជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ឬទេ (ប្រសិនបើ "អំពើអមនុស្សធម៌ផ្សេងៗទៀត" អាចយកមកអនុវត្តបាន ហើយគោលការណ៍នីត្យានុកូលភាពភ្ជាប់ជាមួយនឹងប្រភេទតូចៗនៃអំពីទាំងនោះទេ)?

ន. តើ "អំពើហិង្សាផ្លូវភេទ" ជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលបង្កើតជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិតាមច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅចន្លោះពីឆ្នាំ ១៩៧៥ ដល់ឆ្នាំ ១៩៧៩ ឬទេ (ប្រសិនបើ "អំពើអមនុស្សធម៌ផ្សេងៗទៀត" អាចយកមកអនុវត្តបាន ហើយគោលការណ៍នីត្យានុកូលភាពភ្ជាប់ជាមួយនឹងប្រភេទតូចៗនៃអំពីទាំងនោះទេ)?

យ. ប្រសិនបើ "ការជម្លៀសដោយបង្ខំ" អាចយកមកអនុវត្តបាននោះ តើមូលដ្ឋាននានាដែលអនុញ្ញាតដោយច្បាប់អន្តរជាតិគឺជាយុត្តិកម្មតែមួយគត់គាំទ្រឲ្យមានការជម្លៀសប្រជាជនដែលសម្រេចពីនីត្យានុកូលភាពតាមច្បាប់មនុស្សធម៌អន្តរជាតិបានឬទេ? និង

រ. ប្រសិនបើ "ការជម្លៀសដោយបង្ខំ" អាចយកមកអនុវត្តបាន តើការទប់ស្កាត់ការខ្វះខាតអាហារ និងការធានានូវការទទួលបានការថែទាំសុខភាព ជាមូលដ្ឋានដែលត្រូវបានអនុញ្ញាតសម្រាប់ការជម្លៀសតាមច្បាប់មនុស្សធម៌អន្តរជាតិបានឬទេ[១៧]?

១១. <u>អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានសម្រេចស្ថាពរនៅឡើយទេចំពោះករណី ថាតើ អ.វ.ត.ក មានយុត្តាធិការអនុវត្តការរំលោភបំពានលើអនុសញ្ញាទីក្រុងហ្សឺណែវប្រឆាំងនឹងលោក អៀង សារី ដែរឬទេ[១៨] ។</u>

១២. <u>អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានសម្រេចស្ថាពរនៅឡើយទេចំពោះករណី ថាតើនឹងត្រូវលុប</u>

---

[១៧] *សូមមើល* សេចក្តីសង្ខេបអញ្ញត្រកម្មតាមវិធាន ៨៩ របស់លោក អៀង សារី, កថាខណ្ឌ ២៧។

[១៨] ដូចជើងទំព័រខាងលើ កថាខណ្ឌ ២៥

ចោលផ្នែកខ្លះក្នុងដីកាដំណោះស្រាយដោយសារកំហុសនីតិវិធី ដែរឬទេ[១៩]។

### ខ. ក្របខណ្ឌនៃសវនាការ

១៣. ភាគីមិនទាន់បានទទួលដំណឹងនៅឡើយទេ ថាតើមានសវនាការលើ "ផ្នែកតូចៗ"[២០] ឬ "សវនាការតូចៗ"[២១] ចំនួនប៉ុន្មាន នឹងត្រូវធ្វើឡើង ហើយមានដាក់បញ្ចូលអ្វីខ្លះនៅក្នុងផ្នែកតូចៗ និងសវនាការតូចៗនីមួយៗ។

១៤. ភាគីមិនទាន់បានទទួលដំណឹងនៅឡើយទេ ថាតើ"ផ្នែកតូចៗ" ឬ "សវនាការតូចៗ" នីមួយៗ នឹងមាន "ចំណុចដែលត្រូវជំនុំជម្រះ" ជាក់លាក់ចំនួនប៉ុន្មាន។

១៥. ភាគីមិនទាន់បានទទួលដំណឹងនៅឡើយទេ ថាតើសវនាការលើ "ផ្នែកតូចៗ" ឬ "សវនាការតូចៗ" ជាប់ទាក់ទងគ្នាយ៉ាងដូចម្តេច ***ជាពិសេស៖***

ក. កន្លងមក អង្គជំនុំជម្រះសាលាដំបូងបានលើកឡើងថា ខ្លួននឹងព្យាយាមស្តាប់ចម្លើយសាក្សីម្នាក់ៗតែម្តងប៉ុណ្ណោះ[២២] ប៉ុន្តែក្រោយមកទៀត អង្គជំនុំជម្រះថ្លែងថា "ក្នុងករណី

---

[១៩] *សូមមើល* ញត្តិរបស់ អៀង សារី ស្នើសុំលុបចោលផ្នែកខ្លះនៃដីកាដំណោះស្រាយដោយសារកំហុសនីតិវិធី ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១១ ឯកសារលេខ E58។ អង្គជំនុំជម្រះសាលាដំបូង បានដោះស្រាយរួចហើយនូវផ្នែកនៃញត្តិនេះទាក់ទងនឹងបទល្មើសជាតិ ប៉ុន្តែមិនទាន់បានដោះស្រាយនូវសំណើទាក់ទងនឹងឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ការទទួលខុសត្រូវរបស់ថ្នាក់លើ សហឧក្រិដ្ឋកម្មរួម ("JCE") និងការធ្វើផែនការ ការញុះញង់ ការជួយនិងការជម្រុញ និងការបញ្ជានៅឡើយ។

[២០] ដីកាបំបែកកិច្ចដំណើរការនីតិវិធី អនុលោមតាមវិធាន ៨៩ ស្ទួនពីរនៃវិធានផ្ទៃក្នុង ឯកសារលេខ E124 កថាខណ្ឌ ២

[២១] សារអេឡិចត្រូនិចស្តីពីការកំណត់កាលបរិច្ឆេទ ទំព័រទី ១

[២២] ក្នុងកិច្ចប្រជុំរៀបចំសវនាការ ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង បានថ្លែងថា "ជាវិធានការទូទៅអង្គជំនុំជម្រះ សូមបញ្ជាក់ថាខ្លួននឹងស្តាប់ចម្លើយសាក្សីម្នាក់ៗតែម្តងប៉ុណ្ណោះពាក់ព័ន្ធទៅនឹងគ្រប់បញ្ហាទាំងអស់ដែលសាក្សីនោះ អាចផ្តល់សក្ខីកម្មបាន ដោយមិនកោះហៅសាក្សីនោះមកជាច្រើនដងទេ។" ប្រតិចារិត ឯកសារលេខ E1/2.1 ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១១ ទំព័រ៥៣

ចាំបាច់ អង្គជំនុំជម្រះសាលាដំបូងនឹងអនុញ្ញាតឲ្យកោះហៅសាក្សីម្តងទៀតដើម្បីសួរដេញដោលដោយលម្អិតនូវចំណុចនានា ដែលត្រូវដាក់បញ្ចូលក្នុងសវនាការក្រោយៗទៀត"[២៣]។ ការស្តាប់ចម្លើយសាក្សីម្នាក់នៅក្នុងសវនាការលើ "ផ្នែកតូចៗ" ឬ "សវនាការតូចៗ" **តែមួយលើក** ហាក់បីដូចជាផ្ទុយទៅនឹងជំហររបស់អង្គជំនុំជម្រះសាលាដំបូង ដែលកន្លងមកបានលើកឡើងថា ខ្លួននឹងមិនធ្វើការកត់សម្គាល់នូវអង្គហេតុដែលបានវិនិច្ឆ័យរួចហើយឡើយ ដោយហេតុថា "មិនមានមូលដ្ឋានផ្លូវច្បាប់ឡើយនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬនៅក្នុងវិធានផ្ទៃក្នុង សម្រាប់ឲ្យអង្គជំនុំជម្រះធ្វើការកត់សម្គាល់នូវអង្គហេតុដែលបានវិនិច្ឆ័យរួចហើយ ឬអង្គហេតុដែលបានដឹងឮជាទូទៅយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក នោះទេ"[២៤]។

ខ. តើសវនាការដំណាក់កាលដំបូង "ផ្តល់មូលដ្ឋានជាទូទៅមួយចំពោះបទចោទទាំងអស់ រួមទាំងបទចោទដែលនឹងត្រូវដេញដោលក្នុងពេលសវនាការពេលក្រោយមក"[២៥] បានយ៉ាងដូចម្តេច បើសិនជាអង្គជំនុំជម្រះ នឹងមិនធ្វើការកត់សម្គាល់ចំពោះអង្គហេតុដែលបានវិនិច្ឆ័យរួចហើយ ដោយហេតុថាខ្លួនមិនអាចធ្វើការកត់សម្គាល់ចំពោះអង្គហេតុដែលបានវិនិច្ឆ័យរួចហើយនោះ? ដំណើរការបណ្តឹងសាទុក្ខ ក៏ជាបញ្ហាចោទបន្ថែមផងដែរ៖ តើសំអាងហេតុ និងសេចក្តីសន្និដ្ឋាននៃច្បាប់ក្នុងសវនាការដំណាក់កាលដំបូង អាចប្រើប្រាស់ក្នុងសវនាការដំណាក់ទីពីរបានយ៉ាងដូចម្តេច ខណៈដែលសំអាងហេតុ និងសេចក្តីដ្ឋាននោះ

---

[២៣] អនុស្សរណៈ: អង្គជំនុំជម្រះសាលាដំបូង បញ្ជីសាក្សីរបស់សវនាការដំណាក់កាលដំបូង កាលកំណត់កាលបរិច្ឆេទសម្រាប់ការជំទាស់ទៅនឹងភាពអាចទទួលយកបានចំពោះឯកសារ និងភស្តុតាង និងចម្លើយតបទៅនឹងញាតិ ឯកសារលេខ E109/5 ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១ ឧបសម្ព័ន្ធសម្ងាត់ ខ។

[២៤] សេចក្តីសម្រេចលើសំណើរបស់អៀង សារី ទាក់ទិននឹងការយកអង្គហេតុពីសំណុំរឿងលេខ០០១ ដែលបានវិនិច្ឆ័យរួចហើយ និងអង្គហេតុនៃការដឹងឮជាទូទៅមកអនុវត្តក្នុងសំណុំរឿង០០២ ឯកសារលេខ E69/1 ថ្ងៃទី ៤ ខែ មេសា ឆ្នាំ ២០០១ ទំព័រទី៣ "**យល់ឃើញផងដែរថា** មិនមានមូលដ្ឋានផ្លូវច្បាប់ឡើយនៅក្នុងច្បាប់ស្តីពីការបង្កើត អ.វ.ត.ក ឬនៅក្នុងវិធានផ្ទៃក្នុងសម្រាប់ឲ្យអង្គជំនុំជម្រះធ្វើការកត់សម្គាល់នូវអង្គហេតុដែលបានវិនិច្ឆ័យរួចហើយ ឬអង្គហេតុដែលបានដឹងឮជាទូទៅយកមកអនុវត្តនៅចំពោះមុខ អ.វ.ត.ក នោះទេ ដូចបានលើកឡើងនៅក្នុងសំណើទាំងពីររបស់មេធាវីការពារក្តី"។

[២៥] សារអេឡិចត្រូនិកស្តីពីការកំណត់កាលបរិច្ឆេទ ទំព័រទី ១។

អាចត្រូវពិនិត្យមើលឡើងវិញតាមរយៈការដាក់បណ្ដឹងសាទុក្ខនោះ?

១៦. ភាគីមិនទាន់បានទទួលដំណឹងគ្រប់គ្រាន់ ដោយហេតុថាដីកាបំបែកកិច្ចដំណើរការនីតិវិធីពុំបញ្ជាក់ច្បាស់ថាតើអង្គជំនុំជម្រះសាលាដំបូង នឹងពិនិត្យមើលគោលនយោបាយកម្ពុជាប្រជាធិបតេយ្យទៅលើបញ្ហាទាំងអស់ដែលបានលើកឡើងក្នុងដីកាបញ្ជូនរឿងឲ្យទៅជំនុំជម្រះដែរឬទេ ឬគ្រាន់តែពិនិត្យមើលបញ្ហាដែលទាក់ទងនឹងសវនាការដំណាក់កាលដំបូងតែប៉ុណ្ណោះ[២៦]។

១៧. ភាគីមិនទាន់បានទទួលដំណឹងថាតើសវនាការ នឹងត្រូវបានធ្វើឡើងប៉ុន្មានលើក ហើយមួយលើកៗមានរយៈពេលប៉ុន្មានម៉ោង។

១៨. ភាគីមិនទាន់បានទទួលដំណឹងនៅឡើយទេ ថាតើអង្គជំនុំជម្រះនឹងកំណត់រយៈពេលទៀងទាត់សម្រាប់កិច្ចប្រជុំរៀបចំសវនាការ ឬសម្រាប់លើកឡើងនូវការជំទាស់ទៅនឹងឯកសារ ដូចបានស្នើឡើងដោយភាគីភាគច្រើនឬទេ[២៧]។

---

[២៦] *សូមមើល* សំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យបញ្ជាក់ពីវិសាលភាពនៃសវនាការដំបូង ថ្ងៃទី ៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E124 ។ ក្រុមមេធាវីការពារក្ដី យល់ស្របនឹងក.ស.ព ថាមានបញ្ហាជាច្រើនមិនមានភាពច្បាស់លាស់នៅក្នុងដីកាបំបែកកិច្ចដំណើរការនីតិវិធី ក៏ប៉ុន្តែក្រុមមេធាវីការពារក្ដី យល់ឃើញថាសំណើនោះជាការបំពានកិច្ចដំណើរការ ដោយហេតុថាវាត្រូវបានមើលឃើញថាជាការសម្រេចឡើងវិញនូវដីកាបំបែកកិច្ចដំណើរការនីតិវិធីជាលើកទី២។ *សូមមើល* ចម្លើយតបរបស់ក្រុមមេធាវីការពារក្ដីទៅនឹងសំណើរបស់សហព្រះរាជអាជ្ញាសុំឲ្យបញ្ជាក់ពីវិសាលភាពនៃសវនាការដំបូង ដែលត្រូវដាក់នៅពេលឆាប់ៗខាងមុខនេះ។

[២៧] *សូមមើល* លិខិតពីក្រុមមេធាវីការពារក្ដី អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់ មានចំណងជើងថា "ការរៀបចំកាលបរិច្ឆេទសវនាការលើអង្គសេចក្ដី" ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០១១។ លិខិតពីក្រុមមេធាវីការពារក្ដី អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់មានចំណងជើងថា "សំណើសុំការបញ្ជាក់អំពីអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើង "បញ្ជីសាក្សីសម្រាប់សវនាការដំណាក់កាលដំបូង, កាលបរិច្ឆេទផុតកំណត់សម្រាប់ការជំទាស់ទៅនឹងភាពអាចទទួលយកបាននៃឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងញត្តិ ឯកសារលេខ E109/5" " ថ្ងៃទី ២១ ខែ តុលា ឆ្នាំ២០១១។ សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឲ្យមានការប្រជុំស្ដីពីការរៀបចំសវនាការ និងការប្រជុំទៀងទាត់នានាស្ដីពីស្ថានភាពសវនាការសម្រាប់សំណុំរឿង០០២ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E132។ ចម្លើយតបរបស់អៀង សារី ទៅនឹង សំណើរបស់សហព្រះរាជអាជ្ញា ស្នើសុំឲ្យមានការប្រជុំស្ដីពីការរៀបចំសវនាការ និងការប្រជុំទៀងទាត់នានាស្ដីពីស្ថានភាពសវនាការសម្រាប់សំណុំរឿង០០២ ថ្ងៃទី ២៤

### គ. ការទទួលយកភស្តុតាង

១៩. ភាគីមិនទាន់ត្រូវបានជូនដំណឹងថាតើអង្គជំនុំជម្រះសាលាដំបូង នឹងទទួលយកជាភស្តុតាងនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី ក្នុងករណីសាក្សីដែលត្រូវបានសាកសួរ មិនត្រូវបានកោះហៅឲ្យផ្តល់សក្ខីកម្មដែរឬទេ[២៨]។

២០. ភាគីមិនទាន់ត្រូវបានជូនដំណឹងថាតើកំណត់ហេតុស្តាប់ចម្លើយសាក្សីក្នុងសំណុំរឿង០០៣ និង ០០៤ ដែលជាប់ទាក់ទងនឹងសាក្សីក្នុងសំណុំរឿង០០២ នឹងត្រូវបង្ហាញដល់ភាគីក្នុងសំណុំរឿង ០០២ ដែរឬទេ[២៩]។

---

ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E132/1។ សំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណី ស្នើឲ្យមានកិច្ចប្រជុំសវនាការ និងការប្រជុំទៀងទាត់នានាស្តីពីស្ថានភាពសវនាការសម្រាប់សំណុំរឿង០០២ និងការស្នើសុំការបញ្ជាក់ស្តីពីការកំណត់ពេលវេលា និងការរៀបចំសវនាការ ថ្ងៃទី ២៨ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E132/2។ ការជំទាស់ ការសង្កេត និងការជូនដំណឹងអំពីឯកសារដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១ ឯកសារលេខ E131/1/9។

[២៨] *សូមមើល ឧទាហរណ៍* សេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធនឹងការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ថ្ងៃទី ១៥ ខែ មិថុនា ឆ្នាំ ២០១១ ឯកសារលេខ E96។ ចម្លើយតបរបស់លោក អៀង សារី ចំពោះសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា អនុលោមតាមវិធាន ៩២ ពាក់ព័ន្ធ នឹង ការទទួលយកកំណត់ហេតុស្តាប់ចម្លើយសាក្សីនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង និងសំណើសុំឲ្យបើកសវនាការដេញដោលផ្ទាល់មាត់ជាសាធារណៈ ថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ ឯកសារលេខ E96/3។

[២៩] *សូមមើល* ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិដល់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយនៃសាក្សីនៃសំណុំរឿង ០០២ ចូលក្នុងសំណុំរឿង០០៣ និង០០៤ ដោយមានឧបសម្ព័ន្ធ ក សម្ងាត់បំផុត ថ្ងៃទី ៦ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E127។ ចម្លើយតបរបស់អៀង សារី ចំពោះ ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិដល់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយនៃសាក្សីនៃសំណុំរឿង ០០២ ចូលក្នុងសំណុំរឿង០០៣ និង០០៤ ដោយមានឧបសម្ព័ន្ធ ក សម្ងាត់បំផុត ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E127/1 ។ ចម្លើយតបរបស់ក្រុមមេធាវី អៀង ធីរិទ្ធ ចំពោះ ការបង្ហាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិដល់អង្គជំនុំជម្រះសាលាដំបូងទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយនៃសាក្សីនៃសំណុំរឿង ០០២ ចូលក្នុងសំណុំរឿង០០៣ និង០០៤ ដោយមានឧបសម្ព័ន្ធ ក សម្ងាត់បំផុត ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១ ឯកសារលេខ E127/3។

២១. <u>អង្គជំនុំជម្រះសាលាដំបូង មិនទាន់បានបញ្ជាក់ច្បាស់ថាតើភាគីអាចដាក់ឯកសារដោយវិធីណា[៣០]។</u>

២២. <u>អង្គជំនុំជម្រះសាលាដំបូងមិនទាន់បានបញ្ជាក់ច្បាស់ ថាតើភាគីគប្បីធ្វើការជំទាស់នឹងឯកសារយ៉ាងដូចម្តេច ក្នុងករណីដែលក.ស.ព និងដើមបណ្តឹងរដ្ឋប្បវេណី បានដាក់ឯកសារចំនួនច្រើនពេកដោយមិនសមស្របក្នុងបញ្ជីឯកសារ ដែលត្រូវដាក់បង្ហាញក្នុងសវនាការដំណាក់កាលដំបូង។</u>

២៣. <u>អង្គជំនុំជម្រះសាលាដំបូងមិនទាន់សម្រេចថាតើក្រុមមេធាវីការពារក្តីនឹងត្រូវបានអនុញ្ញាតឱ្យពិនិត្យមើលឯកសារសម្ងាត់បំផុតដែរឬទេ[៣១]។</u>

### ឃ. ការផ្តល់សក្ខីកម្មរបស់សាក្សី

២៤. <u>អង្គជំនុំជម្រះសាលាដំបូងមិនទាន់ចេញដីកាសម្រេចស្តីពីការជំទាស់របស់ភាគីទៅនឹងសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញនៅឡើយទេ។</u>

២៥. <u>អង្គជំនុំជម្រះសាលាដំបូង គ្រាន់តែបានជូនដំណឹងភាគីអំពីដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សី ដែលខ្លួនមានបំណងកោះហៅក្នុងអំឡុងសវនាការរយៈពេលបីសប្តាហ៍ដំបូង ប៉ុន្តែមិនបានបញ្ជាក់ជូនភាគីថាតើភាគីនឹងទទួលបានការជូនដំណឹងអំពីសាក្សីដែលត្រូវកោះហៅនៅពេលក្រោយៗទៀតនៅពេលណា និងមិនបានបញ្ជាក់ជូនភាគីអំពីលំដាប់លំដោយនៃការកោះហៅសាក្សីឡើយ[៣២]។</u>

---

[៣០] *សូមមើល* សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យបង្កើតប្រព័ន្ធមានប្រសិទ្ធិភាពមួយសម្រាប់ការទទួលយកភស្តុតាងជាឯកសារនៅពេលសវនាការ ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ២០១១ (ជូនដំណឹងនៅថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ២០១១ ឯកសារលេខ E136) *សូមមើលផងដែរ* ចម្លើយតបរបស់អៀង សារី ទៅនឹង សំណើរបស់សហព្រះរាជអាជ្ញា សុំឱ្យបង្កើតប្រព័ន្ធមានប្រសិទ្ធិភាពមួយសម្រាប់ការទទួលយកភស្តុតាងជាឯកសារនៅពេលសវនាការ, ឯកសារនោះនឹងត្រូវដាក់នៅពេលឆាប់ៗខាងមុខ។

[៣១] *សូមមើល* សំណើរបស់លោកអៀង សារី សុំពិនិត្យមើលឯកសារសម្ងាត់បំផុតក្នុងសំណុំរឿង ថ្ងៃទី ១៤ ខែ កញ្ញា ឆ្នាំ ២០១១ ឯកសារលេខ E118។

[៣២] ក្រុមមេធាវីការពារក្តី បានស្នើឱ្យអង្គជំនុំជម្រះសាលាដំបូង ជូនដំណឹងភាគីរយៈពេលមួយខែជាមុនអំពីដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដែលខ្លួនមានបំណងកោះហៅក្នុងខែក្រោយ ដើម្បីឱ្យក្រុមមេធាវីការពារក្តីមានពេលវេលាគ្រប់គ្រប់រៀបចំ។ *សូមមើល* លិខិតពីក្រុមមេធាវីការពារក្តី អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់ មានចំណងជើងថា "ការរៀបចំការបរិច្ឆេទសម្រាប់ **សំណើរបស់លោក អៀង សារី ស្នើសុំឱ្យមានដំណោះស្រាយភ្លាមៗ និងមានសេចក្តីសម្រេចដែលមានសំអាងហេតុគ្រប់គ្រាន់ចំពោះបញ្ហានានាដែលនៅមិនទាន់បានដោះស្រាយ មុនពេលចាប់ផ្តើមដំណើរការសវនាការ**

២៦. ភាគីមិនទាន់បានទទួលដំណឹងនៅឡើយទេ ថាតើពេលវេលាចំនួនប៉ុន្មានដែលនឹងត្រូវផ្តល់ឲ្យក្នុងការសាកសួរជនជាប់ចោទនីមួយៗ។

២៧. ភាគីមិនទាន់បានទទួលដំណឹងនៅឡើយទេ ថាតើត្រូវបែកចែកពេលវេលាឲ្យភាគីនីមួយៗយ៉ាងដូចម្តេច។

២៨. ភាគីមិនទាន់បានទទួលដំណឹងនៅឡើយទេ អំពីលំដាប់លំដោយដែលខ្លួននឹងត្រូវសាកសួរជនជាប់ចោទនីមួយៗ។

២៩. ភាគីមិនទាន់បានទទួលដំណឹងនៅឡើយទេ ថាតើអង្គជំនុំជម្រះសាលាដំបូង នឹងអនុវត្តវិធីសាស្រ្តសាកសួរជនជាប់ចោទក្នុងសំណុំរឿង ០០២ ដូចបានអនុវត្តក្នុងសំណុំរឿង០០១ ដែរឬទេ[៣៣]។

៣០. ភាគីមិនទាន់បានទទួលដំណឹងនៅឡើយទេ ថាតើជនជាប់ចោទ នឹងត្រូវកោះហៅច្រើនដងក្នុង "សវនាការតូច" នីមួយៗដែរឬទេ។

៣១. ភាគីមិនទាន់បានទទួលដំណឹងនៅឡើយទេ ថាតើលើកដំបូង ភាគីត្រូវសាកសួរជនជាប់ចោទអំពីចំណុចអ្វីខ្លះ ក្នុងករណីជនជាប់ចោទត្រូវបានសាកសួរច្រើនជាងមួយលើក។

៣២. ភាគីមិនទាន់បានទទួលដំណឹងនៅឡើយទេ ថាតើសាក្សីក្នុងសវនាការដំណាក់កាលដំបូង នឹងត្រូវ

---

សវនាការលើអង្គសេចក្តី" ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០១១។ លិខិតពីក្រុមមេធាវីការពារក្តី អៀង សារី ផ្ញើជូនមន្ត្រីច្បាប់ជាន់ខ្ពស់ "សំណើសុំការបញ្ជាក់អំពីអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង មានចំណងជើង "បញ្ជីសាក្សីសម្រាប់សវនាការដំណាក់កាលដំបូង, កាលបរិច្ឆេទផុតកំណត់សម្រាប់ការជំទាស់ទៅនឹងភាពអាចទទួលយកបាននៃឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងញត្តិ ឯកសារលេខ E109/5" ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១១។

[៣៣] ក្នុងសំណុំរឿង០០១ ឌុច ត្រូវសាកសួរជាបឋមរយៈពេលពីថ្ងៃកន្លះ ហើយបន្ទាប់មកទៀត ត្រូវបានសាកសួរជាបន្តបន្ទាប់ក្នុងអំឡុងពេលសវនាការ។

បានកោះហៅម្តងទៀត សម្រាប់សវនាការដំណាក់កាលក្រោយៗទៀតដែរឬទេ ឬថាតើសាក្សីនីមួយៗ នឹងត្រូវបង្ហាញខ្លួនផ្តល់សក្ខីកម្មតែមួយលើកប៉ុណ្ណោះ សម្រាប់គ្រប់ប្រធានបទ/អង្គហេតុ (ក្នុងសវនាការទាំងមូល) ដែលសមស្របចំពោះសាក្សីក្នុងផ្តល់សក្ខីកម្ម ឬយ៉ាងណា។

៣៣. ភាគីមិនទាន់បានទទួលដំណឹងនៅឡើយទេ អំពីលំដាប់លំដោយដែលសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី ត្រូវផ្តល់សក្ខីកម្មក្នុងសវនាការដំណាក់កាលដំបូង[៣៤]។

៣៤. ភាគីមិនទាន់បានទទួលដំណឹងនៅឡើយទេ ថាតើខ្លួនទទួលបានរយៈពេលប៉ុន្មានដើម្បីសាកសួរជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីនីមួយៗ ក្នុងសវនាការដំណាក់កាលដំបូង ហើយពេលវេលានេះនឹងត្រូវពេលបែងចែកយ៉ាងដូចម្តេច។

### ង.បញ្ហាដទៃទៀតដែលមិនទាន់បានដោះស្រាយ

៣៥. ភាគីមិនទាន់បានទទួលដំណឹងនៅឡើយទេ ថាតើអង្គជំនុំជម្រះសាលាដំបូងនឹងបង្គាប់ឲ្យចុះពិនិត្យដល់ទីកន្លែងដែរឬទេ[៣៥]។

៣៦. ភាគីមិនទាន់បានទទួលដំណឹងនៅឡើយទេ ថាតើលោកស្រី អៀង ធីរិទ្ធ មានសម្បទាគ្រប់គ្រាន់ដើម្បីឲ្យតុលាការជំនុំជម្រះក្តីដែរឬទេ។

៣៧. អង្គជំនុំជម្រះសាលាដំបូងមិនបានបញ្ជាក់នៅនៅឡើយទេអំពី លក្ខណៈ និងវិសាលភាព នៃជំនួប

---

[៣៤] ទាក់ទងនឹងចំណុចនេះ ឧបសម្ព័ន្ធសម្ងាត់ ខ មិនមានភាពច្បាស់លាស់ឡើយ។ ជាបឋម អង្គជំនុំជម្រះ ថ្លែងថាបន្ទាប់ពីសាកសួរជនជាប់ចោទ អង្គជំនុំជម្រះ នឹងបន្តកោះហៅដើមបណ្តឹងរដ្ឋប្បវេណី និងសាក្សីដែលមានក្នុងបញ្ជី ប៉ុន្តែ "មិនចាំបាច់តាមលំដាប់លំដោយក្នុងបញ្ជីឡើយ"។ ទោះបីយ៉ាងណា បន្ទាប់មកទៀត អង្គជំនុំជម្រះ ថ្លែងថា "ក្នុងករណីផ្លាស់ប្តូរលំដាប់លំដោយនៃការកោះហៅសាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី នឹងត្រូវជូនដំណឹងដល់ភាគីឲ្យបានឆាប់តែអាចធ្វើបាន"។

[៣៥] *សូមមើល* សំណើរបស់អៀង សារី សុំឲ្យអង្គជំនុំជម្រះសាលាដំបូងចុះពិនិត្យដល់ទីកន្លែង ឯកសារលេខ E113។

<u>សម្ងាត់រវាងសហព្រះរាជអាជ្ញាអន្តរជាតិ និងលោកស្រី Cartwright ចៅក្រមអន្តរជាតិ[៣៦]។</u>

**អាស្រ័យហេតុនេះ** ដូចសំអាងហេតុដែលបានលើកឡើងខាងលើនេះ មេធាវីការពារក្តីសូមស្នើដោយក្តីគោរពចំពោះអង្គជំនុំជម្រះសាលាដំបូងមេត្តា៖

ក. **ដោះស្រាយ**សំណួរ និងបញ្ហានានាដែលបានលើកឡើងខាងលើ មុនពេលចាប់ផ្តើមកិច្ចដំណើរការសវនាការលើអង្គសេចក្តី។ ឬជាជម្រើសផ្សេងមួយទៀតនោះគឺ

ខ. **បើក**កិច្ចប្រជុំរៀបចំសវនាការប្រកបដោយអត្ថន័យមួយ មុនពេលចាប់ផ្តើមសវនាការក្នុងសំណុំរឿង ០០២ ដែលបានកំណត់កាលបរិច្ឆេទសម្រាប់ការធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ នៅថ្ងៃទី ២១ ខែ វិច្ឆិកា ឆ្នាំ ២០១១។

សូមចៅក្រមអង្គជំនុំជម្រះសាលាដំបូងទទួលយកសំណើនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី **១៦** ខែ **វិច្ឆិកា** ឆ្នាំ **២០១១**

សហមេធាវីការពារក្តីរបស់លោក **អៀង សារី**

| | |
|---|---|
| **អាង ឧត្តម** | **Michael G. KARNAVAS** |

[៣៦] *សូមមើល* សំណើសុំព័ត៌មានទាក់ទិននឹងជំនួបសម្ងាត់រវាងលោកស្រីចៅក្រម SILVIA CARTWRIGHT សហព្រះរាជអាជ្ញាបរទេស និងអនុប្រធានរដ្ឋបាល ឯកសារលេខ E137/1។